**BMI0086**

# សម្ភាសន៍ជាមួយឈ្មោះ ឈូក ជិន ភេទប្រុស អាយុ៨៩ឆ្នាំ

មុខងារជំនាន់ខ្មែរក្រហម“កងចល័ត”

ស្រុកកំណើតនៅភូមិស្តៅ ឃុំគោកកថិន ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

រស់ភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:១៨:៥៧

១០ទំព័រ

ប៊ុនថនៈ ពូឈ្មោះអីដែរ?

ជិនៈ ឈូក ជិន ។

ប៊ុនថនៈ ពូអាយុប៉ុន្មានហើយ?

ជិនៈ អាយុ៨៩ឆ្នាំ ។

ប៊ុនថនៈ មានភូមិកំណើតនៅណា?

ជិនៈ នៅស្តៅ ។

ប៊ុនថនៈ ភូមិឃុំអីដែលពូ?

ជិនៈ ឃុំទ្រៀស ឃុំគោកថិននេះឯង ។

ប៊ុនថនៈ បាទ ។

ជិនៈ ឃុំគោកថិន ។

ប៊ុនថនៈ ស្រុកស្វាយចេក?

ជិនៈ ទេ ស្រុកថ្មពួក ។

ប៊ុនថនៈ ស្រុកកំណើតភូមិអីដែរ?

ជិនៈ ភូមិស្តៅនៅស្តៅ ។

ប៊ុនថនៈ មិនមែននៅភូមិផ្គាំនេះទេ?

ជិនៈ អត់ទេ ភូមិស្តៅ ។

ប៊ុនថនៈ ខ្ញុំមិនបានរៀនសូត្រដល់ណាដែរ?

ជិនៈ ខ្ញុំមិនបានរៀនសូត្រជ្រៅជ្រះប៉ុន្មានទេ ខ្ញុំរៀនបានថ្នាក់ទី៣ ។

ប៊ុនថន: ថ្នាក់ទី៣?

ជិន: បាទ ។

ប៊ុនថន: រៀននៅសាលាណាដែរ?

ជិន: រៀននៅសាលាស្ពោ ។

ប៊ុនថន: ចឹងបងប្អូនមានបានរៀនទេពូ?

ជិន: បានរៀនខ្លះហ្នឹងឯងបង១ខ្ញុំណាស់ ។

ប៊ុនថន: បាទ ។

ជិន: តែរៀនបានតិចណាស់ រៀនបាត់ឃើញ១ចឹង ខ្ញុំចេញតាំងពីតូចផងតាំងពីកាំភ្លើងអូសជីខ្ញុំចេញតាំងពីតូចខ្ញុំមិនសូវដឹងថាបងនៅរៀនសូត្របុ៉ន្មានខ្ញុំក៏មិនដឹងរឿងគាត់ ។

ប៊ុនថន: បាទ ។

ជិន: ខ្ញុំមិនបានដឹងទេ ។

ប៊ុនថន: ពូមានបងប្អូនប៉ុន្មាននាក់ពូ?

ជិន: បងប្អូនមាន៤នាក់ ។

ប៊ុនថន: ចឹងឪពុកម្ដាយពូធ្វើការឬមួយគាត់ជាអ្នករកស៊ី?

ជិន: ស្លាប់អស់ហើយ ។

ប៊ុនថន: បាទ!តែចង់ដឹងពីមុនមក?

ជិន: កាលពីមុនមកនោះគាត់ជាទាហានដូចតែខ្ញុំចេះឯង ។

ប៊ុនថន: គាត់ជាទាហានដែរ?

ជិន: បាទ!ដល់គាត់ស្លាប់បានខ្ញុំចេញប្រុច ។

ប៊ុនថន: ចឹងពូចូលតាំងពីឆ្នាំណាពូ?

ជិន: ៨១ ។

ប៊ុនថន: ពីមុនសម័យលន់ នល់?

ជិន: បាទ!ពីឆ្នាំ៨១ដែលខ្ញុំចូលធ្វើជាទាហាននេះ ។

ប៊ុនថន: បាទ ។

ជិន: ឆ្នាំ៨១ ។

ប៊ុនថន: ចឹងកាលសម័យលន់ នល់ពូនៅក្មេង១?

ជិន: បាទ!ខ្ញុំនៅក្មេង ។

ប៊ុនថន: ចឹងកាលសម័យប៉ីឆ្នាំនោះពូនៅណាដែរ?

ជិនៈ នៅនោះឯងនៅក្នុងភូមិ ។

ប៊ុនថន: គេមានជម្លៀសចេញដែលពូ?

ជិនៈ អត់មានទេ ។

ប៊ុនថន: ចឹងកាលនៅភូមិពូអាយុប៉ុន្មានហើយកាលរំដោះ៧៥ហ្នឹង?

ជិនៈ កាល៧៥ហ្នឹងខ្ញុំស្រពិចស្រពិលហ្នឹងណាស់ខ្ញុំនៅក្មេងៗ វានៅក្មេងខ្ញុំណាស់ ។

ប៊ុនថន: កាលនៅក្នុងភូមិពូធ្វើអីដែរពូ?

ជិនៈ ធ្វើស្រែ ។

ប៊ុនថន: ក្រៅពីធ្វើស្រែមានធ្វើអីទៀតដែលពូ?

ជិនៈ ចេញពីធ្វើស្រែទៅរត់ឌុបប្រុក ។

ប៊ុនថន: ចឹងឪពុកម្ដាយពូនៅជុំគ្នាជាមួយឪពុកម្ដាយហ្នឹង?

ជិនៈ ឪពុកម្ដាយខ្ញុំនៅជុំគ្នាហ្នឹងឯងតែសព្វថ្ងៃគាត់ស្លាប់អស់ហើយ ។

ប៊ុនថន: ចឹងកាល៨១ហ្នឹងពូចូលនៅណា?

ជិនៈ នៅភ្នំដងរែក ។

ប៊ុនថន: ភ្នំដងរែក?

ជិនៈ បាទ ។

ប៊ុនថន: ម៉េចបានជាពូចង់ទៅធ្វើទាហានពូ?

ជិនៈ មិនដឹងជាមានចិត្តបំណងថាយ៉ាងណា មានគេអ្នកអូសទាញចេះតែទៅក្មេងដែលឆោតចេះតែទៅតាមគេទៅណាស់ ។

ប៊ុនថន: អូសទាញយ៉ាងម៉េចវិញពូ?

ជិនៈ អូសទាញគេនាំទៅណា ដល់គេនាំទៅតាមគេទៅណាស់ ។

ប៊ុនថន: សប្បាយពូ?

ជិនៈ នោះឯងសប្បាយបានទៅរហូតចុះមកពីនោះមករហូតបានមកនៅភ្នំឆត្រនេះ ។

ប៊ុនថន: កាលហ្នឹងពូអាយុប៉ុន្មានកាលឆ្នាំ៨១ប៉ុនអាអូននេះនៅឬធំហើយមានគ្រួសារនៅ?

ជិនៈ ទេ មិនទាន់មានណា រកអាយុខ្លួនឯងមិនឃើញទេចាប់ត្រង់នោះទៅ ។

ប៊ុនថន: បាទ!កាលទៅនៅភ្នំដងរែកហ្នឹងទៅនៅជាមួយខាងណា?

ជិនៈ នៅជាមួយតា សារឿន ។

ប៊ុនថន: កាលហ្នឹងគេហៅកងពលវរៈអីលេខប៉ុន្មានពូ?

ជិន: វរៈ៣៦ ។

ប៊ុនថន: ៣៦?

ជិន: បាទ!៣៦ ។

ប៊ុនថន: កងពលលេខប៉ុន្មានពូ?

ជិន: កងពលលេខ៣៧ ។

ប៊ុនថន: ពូទៅនៅភ្នំដងរែកហ្នឹងបានយូរទេពូ?

ជិន: នៅបានបីឆ្នាំតែបានឃើញៗក៏ចុះមកក្រោម ។

ប៊ុនថន: បាទ ។

ជិន: ចុះមកក៏នៅតាមអណ្តូងបរទេះក៏នៅចុះដល់ក្រោមទៅទៀត ។

ប៊ុនថន: ទៅនៅក្រោមហ្នឹងទៅនៅណាវិញពូនៅភូមិស្រុកភូមិឃុំអីដែរ?

ជិន: អត់មានស្រុកអីមានស្រែអីទេ ក៏ដើរចល័តទៅហើយ ។

ប៊ុនថន: បាទ ។

ជិន: ដួនកាលមួយយប់ក៏ឡើងមកវិញមក អត់មានបាននៅហ្នឹងអីទេ ។

ប៊ុនថន: កាលហ្នឹងមានវៃគ្នាមានអីទេពូ?

ជិន: មាន ។

ប៊ុនថន: វៃជាមួយខាងណាវិញពូ?

ជិន: វៃជាមួយពួកឃួនតាមម៉ាដួរបាត់ដំបងឡើងមកលើខាងនេះវិញ មានត្រឹមបាត់ដំបងមកលើនេះ ។

ប៊ុនថន: មកខាងបន្ទាយមានជ័យនេះ?

ជិន: បាទ!វៃតាមស្វាយចេក ថ្មគោល ពួកយើងនេះ នេះឯងពួកខ្ញុំ ។

ប៊ុនថន: ចឹងពូអត់មាននៅមួយកន្លែងទេចល័ត?

ជិន: ចល័តជាប់អត់មាននៅមួយកន្លែងទេ ។

ប៊ុនថន: ច្រើនទេពូ?

ជិន: ច្រើន ។

ប៊ុនថន: មានរាប់រយរាប់ពាន់នាក់ទេ?

ជិន: កើតរាប់ពាន់ដូចជាយ៉ាងវៃថ្មពួកចេះវៃបន្ទាយឆ្មាចេះសុទ្ធតែពាន់ៗ ។

ប៊ុនថន: ចឹងកាលវ៉ៃហ្នឹងមានស្លាប់មានអីច្រើនទេ?

ជិន: មានខ្លះមិនមានខ្លះច្រើនណាស់ ។

ប៊ុនថន: ចឹងកាលវ៉ៃជាមួយវៀតណាមចឹងខាងប៉ុរាអីមានប៉ះគ្នាទេ?

ជិន: មាន ។

ប៊ុនថន: ចឹងវ៉ៃខាងណាឈ្នះខាងណាចាញ់ទៅជាមួយប៉ុរាអីចឹង?

ជិន: ជាមួយខ្មែរក្រហមមិនបានទេ ។

ប៊ុនថន: បាទ ។

ជិន: បើសិនជាទប់ខ្មែរក្រហមបានមុនដំបូងហើយគឺបានបើថាទប់មិនបានហើយមានតែបាក់ហើយពេលហ្នឹង ។

ប៊ុនថន: វ៉ៃនៅណាវិញជាមួយប៉ុរា?

ជិន: វ៉ៃម៉ាជួរកណ្តាលយើងនេះ ។

ប៊ុនថន: កណ្តាល?

ជិន: បាទ ។

ប៊ុនថន: និយាយថា ខស្សាហ៍វ៉ៃគ្នាដែលពូ?

ជិន: វ៉ៃជាប់ជានិច្ចដូចយ៉ាងជានៅឆ្នាំនេះក៏ដូចគ្នា វ៉ៃនៅឆ្នាំដេញពួកកងពលរត់ធ្លាក់ដល់ភូមិថ្មីនោះដេញពីភូមិថ្មីរត់ធ្លាក់ដល់ថ្មពួកនោះកងពល ។

ប៊ុនថន: បាទ!ចឹងមានដែលវ៉ៃមកដល់ឆ្នាំដែលពូ?

ជិន: ដល់ ។

ប៊ុនថន: ចឹងចូលដល់ឆ្នាំដែរ?

ជិន: បាទ ។

ប៊ុនថន: ចុះពូនិយាយថាវ៉ៃហ្នឹងពូមានខ្លាចមានអីដែរ?

ជិន: កាលនោះដូចជាមិនសូវញញើតប៉ុន្មានទេ ។

ប៊ុនថន: បាទ!អត់មានខ្លាចគ្រោះថ្នាក់ទេត្រូវវ៉ៃៗតែម្តង?

ជិន: មិនខ្លាចទេដល់ចុះនោះ ដល់គ្នាច្រើនដូចជាមិនសូវខ្លាចញញើតអីទេ ។

ប៊ុនថន: ចឹងពូវ៉ៃរហូតដល់ឆ្នាំណាបានពូឈប់?

ជិន: ៩៩ ។

ប៊ុនថន: ៩៩?

ជិនៈ បាទ ៗ

ប៊ុនថនៈ ចឹងពូនៅជាមួយគា សារៀនហ្នឹងរហូតតែម្តង?

ជិនៈ បាទ ៗ

ប៊ុនថនៈ ចឹងពូមានទៅណាទៀត?

ជិនៈ មានបានទៅណាទៀត ៗ

ប៊ុនថនៈ ចឹង៩៩ហ្នឹងពូមកនៅនេះវិញពូ?

ជិនៈ បាទ!បានខ្ញុំចប់រហូតទៅខ្ញុំសម្រាកទៅដល់សព្វថ្ងៃហ្នឹង ៗ

ប៊ុនថនៈ ចឹងពូមានគ្រួសារឆ្នាំណាពូ?

ជិនៈ ឆ្នាំ៨០ប៉ុន្មានទេ ឆ្នាំ៨៩មិនដឹងទេ ៨៩នេះហើយ ៗ

ប៊ុនថនៈ ចឹងកាលហ្នឹងពូនៅធ្វើកងទ័ព?

ជិនៈ បាទ ៗ

ប៊ុនថនៈ កាលហ្នឹងរៀបឲ្យប្តូមួយរៀបការដូចឥឡូវពូ?

ជិនៈ កាលនោះអត់មានបានការបានសែនអីទេកាលនោះ ៗ

ប៊ុនថនៈ កាលហ្នឹងយើងស្គាល់គ្នា?

ជិនៈ បាទ ៗ

ប៊ុនថនៈ មានបានរៀបចំទេ?

ជិនៈ អត់មានបានរៀបចំទេ ៗ

ប៊ុនថនៈ ចឹងមីងគាត់នៅក្នុងភូមិប្តូមួយគាត់នៅកងពលដែរ?

ជិនៈ គាត់នៅនេះឯងគេនៅក្នុងភូមិធំនេះឯង ភូមថ្កាំនេះណាស់ ៗ

ប៊ុនថនៈ បាទ!កាល៩៩ពូឈប់វិហ្នឹងពូនៅខាងទាហានដដែល?

ជិនៈ បាទ!ទើបខ្ញុំសម្រាកបាន១ឆ្នាំហើយ ៗ

ប៊ុនថនៈ បាទ ៗ

ជិនៈ សម្រាកបានមួយឆ្នាំហើយ ៗ

ប៊ុនថនៈ នៅពេលផ្តាច់ខ្លួនហ្នឹងពូ?

ជិនៈ បាទ!កាលផ្តាច់ខ្លួនខ្ញុំទៅរៀននៅជុបនោះគេផ្តាច់ខ្លួនមក មកនៅស្វាយចេកដល់ហើយគេរំសាយមកបានមេខ្ញុំនៅក្នុងភូមិធំនេះហើយ ៗ

ប៊ុនថនៈ គាត់ឈ្មោះអី?

ជិនៈ លោកធាញ ។

ប៊ុនថនៈ លូកធាញ?

ជិនៈ លោកធាញ ។

ប៊ុនថនៈ លោកថេង?

ជិនៈ បាទ!ថេង ។

ប៊ុនថនៈ ឥឡូវគាត់នៅក្នុងភូមិនេះ?

ជិនៈ គាត់នៅក្នុងភូមិផ្កាំនេះឯង ។

ប៊ុនថនៈ ស្អីថេង?

ជិនៈ ថេង ។

ប៊ុនថនៈ ផ្ទះគាត់នៅខាងណាវិញលោកពូ?

ជិនៈ នៅរំលងផ្ទះប៉ុន្មានចេះបានទៅដល់ត្រង់នោះ ។

ប៊ុនថនៈ ឈ្មោះ គាត់ថេងតែម្តងពូ?

ជិនៈ ឈ្មោះ ទូច ថេង ។

ប៊ុនថនៈ ទូច ថេង?

ជិនៈ បាទ ។

ប៊ុនថនៈ ពូនៅជាមួយគាត់?

ជិនៈ បាទ ។

ប៊ុនថនៈ គាត់ជាប្រធានពូ?

ជិនៈ បាទ!នោះឯងជាមេរបស់ខ្ញុំ មេដែលដើរចល័តណាស់ ។

ប៊ុនថនៈ ចឹងកាលហ្នឹងពូកូនចៅគេរហូតឬមួយមានកាន់?

ជិនៈ បាទ!ខ្ញុំកូនចៅគាត់ហ្នឹងឯង ។

ប៊ុនថនៈ ពូថេងហ្នឹងគាត់កាន់ខាងអីវិញកាន់ខាងវរៈ?

ជិនៈ កាន់ខាងវរៈ ។

ប៊ុនថនៈ ចឹងពូដូចថាមានកូនចៅគ្រប់គ្រងហ្នឹងគេដែលទេ?

ជិនៈ ខ្ញុំអត់មានអីទេ ។

ប៊ុនថនៈ ចឹងពូកូនចៅគេរហូត?

ជិនៈ ខ្ញុំកូនចៅគេរហូត ។

ប៊ុនថន: ចឹងពូមានដឹងថាភូមិហ្នឹងកាល៧៩ហ្នឹង?

ជិន: ខ្ញុំមិនបានដឹងទេ ខ្ញុំមិនបានដឹងទេ ។

ប៊ុនថន: ចឹងពូវៃហូតដល់បោះឆ្នោត៩៣ហ្នឹងពូនៅតែបន្តវៃហូត?

ជិន: នៅតែវៃ ។

ប៊ុនថន: ចឹងមានប្រជុំមានអីប្រាប់ពីមូលហេតុអីមានវៃទៀតអី?

ជិន: មិនមានទេ ។

ប៊ុនថន: ចឹងសួរបកក្រោយជំនាន់បីឆ្នាំហ្នឹងពូក្រៅពីធ្វើស្រែពូមានធ្វើអីទៀតទេ?

ជិន: អត់មានធ្វើអីទេ ។

ប៊ុនថន: ចុះឪពុកម្ដាយពូគាត់ធ្វើអីវិញ?

ជិន: ឪពុកម្ដាយខ្ញុំនៅធ្វើស្រែចំការធម្មតា ។

ប៊ុនថន: បាទ!ចឹងបងប្អូនពូមានបាត់បង់ទេពូ?

ជិន: អត់មានអីទេ ។

ប៊ុនថន: គាត់នៅជុំគ្នាទាំងអស់ពូ?

ជិន: បាទ ។

ប៊ុនថន: ចឹងពូនៅនេះមានស្គាល់តា ពិនអីទេពូ?

ជិន: មិនដែលស្គាល់ទេ ។

ប៊ុនថន: តា ពិនអីមិនដែលស្គាល់គាត់?

ជិន: មិនដែលស្គាល់ទេ ។

ប៊ុនថន: ចឹងរាល់ថ្ងៃនេះពូមានកូនប៉ុន្មាននាក់ហើយពូ?

ជិន: មាន៩នាក់ ។

ប៊ុនថន: បាទ!ប្រុសប៉ុន្មានស្រីប៉ុន្មានពូ?

ជិន: ប្រុស៨ស្រីតែ១ ។

ប៊ុនថន: បាទ!មានបានរៀនដែលពូ?

ជិន: មានបានរៀនទេ កាលនោះសម័យគ្រាប់ផ្លោង ។

ប៊ុនថន: ចឹងធំៗអស់ហើយ?

ជិន: ធំអស់ហើយ ។

ប៊ុនថន: កូនបងគេអាយុប៉ុន្មាន?

ជិនៈ បងគេនោះអាយុ២០ប៉ុន្មានទេ អានោះបើមិន២៣ក៏២៤ដែរអាបងគេ ។

ប៊ុនថនៈ ចឹងពូឥឡូវធ្វើអីវិញពូចេញពីទាហាន?

ជិនៈ ខ្ញុំធ្វើស្រែ ឈាប់ធ្វើស្រែបាក់ជើងដៃទៅ ទៅណាមិនរួច ។

ប៊ុនថនៈ ពិការពូ?

ជិនៈ បាទ!ពិការ ។

ប៊ុនថនៈ ត្រូវចំណាវិញពូ?

ជិនៈ កន្លែងត្រូវគ្រាប់នេះ ។

ប៊ុនថនៈ ត្រូវពេលណា?

ជិនៈ សម័យគ្រាប់ផ្លោងហ្នឹង ។

ប៊ុនថនៈ ឆ្នាំណា៨០ជាងហើយពូ?

ជិនៈ បាទ!៨៨-៨៩នេះឯង ។

ប៊ុនថនៈ កាលហ្នឹងរ៉ៃនៅណាវិញ?

ជិនៈ អត់មានបានរ៉ៃទេ ឆ្លងមកស្វាយចេកបាំងផ្ទះការំភ្លើងពួកខ្ញុំភ្លូវឲ្យវណែតចេះឯង ។

ប៊ុនថនៈ បាទ ។

ជិនៈ ហើយក៏ជួយបាំងផ្ទះតា ការំភ្លើងពួកខ្ញុំអាមួយនោះវាយកបេដាក់ក្នុងជង្រុករត់ទៅយកការំភ្លើង បេនោះមកបាន ។

ប៊ុនថនៈ ចឹងផ្លោងមកចំ?

ជិនៈ បាទ!ចំកណ្តាលដំបូងផ្ទះនេះឯងកំពង់តែបាំងចេះ ។

ប៊ុនថនៈ បាទ ។

ជិនៈ ចំកណ្តាលដំបូងផ្ទះមានអ្នកកុសល្យមិនបានត្រូវគ្រាប់ចឹងខ្យល់ផាត់មកវាធ្លាក់មកតាមចំហៀង ផ្ទះចេះ ។

ប៊ុនថនៈ បាទ!បានផ្ទុះ?

ជិនៈ ទេ វាផ្ទុះនៅលើនោះហើយ ខ្ញុំរត់មកកន្សែងមួយការំភ្លើងមួយដើមរំដើងខ្ញុំ ខ្ញុំនៅដល់ពេទ្យ ដុបគគីរនេះ ។

ប៊ុនថនៈ កាលហ្នឹងធ្លាក់នៅណាវិញ?

ជិនៈ នៅក្នុងភូមិធំនោះ ។

ប៊ុនថនៈ កាលហ្នឹងនៅខាងខ្មែរក្រហម?

ជិនៈ បាទ ។

ប៊ុនថនៈ តែពូត្រូវរបួសអាចដើរបានដែរ?

ជិនៈ ដើរបានមកពេលដោះទ្រនាប់ជើងចេះក៏ឈាមជាប់ម្រាមជើងអស់ មកដល់ដើមសំបក់ត្រង់នេះសន្ទប់ត្រង់នេះហើយឃើញកងគេមកពីជើងនោះហើយខ្ញុំសុំដោយសារគេបានគេឌុបទៅដល់កន្លែងពេទ្យ ។

ប៊ុនថនៈ មានបានវះកាត់អីទេពូ?

ជិនៈ ទេ គេគ្រាន់តែដេមកបានខ្ញុំទៅចាក់តែថ្នាំរួចខ្ញុំរត់ទៅរកពេទ្យនៅស្ពោនោះចាក់ថ្នាំអស់២០ ប៉ុន្មានម្ភុលទេ ។

ប៊ុនថនៈ បាទ ។

ជិនៈ លែងខ្ញុំខឹងខ្ញុំរើកាំភ្លើងបំបាក់គេរើសបានខ្ញុំប្រុចទៅទៀត ។

ប៊ុនថនៈ កាលនៅភូមិហ្នឹងពូនៅជាទាហានដដែល?

ជិនៈ បាទ!ខ្ញុំនៅជាទាហាន ។

ប៊ុនថនៈ ចឹងមានធ្មើទុកដែលរាល់ថ្ងៃ?

ជិនៈ ធ្មើទុកនេះឯងជួនកាលទៅមានវិញមុខ ។

ប៊ុនថនៈ តែអាចដើរបានដែលពូ?

ជិនៈ ដើរបាន ដើរបានទៅដឹកកណ្ដាប់ដឹកអីចឹង ដើរបានបន្តិចៗនេះ នេះឯងប្រុងឲ្យម៉ែវានេះឯងទៅរកថ្នាំគេតាណុសមកចាក់មួយម្ភុលទៀត ។

ប៊ុនថនៈ បាទ ។

ជិនៈ ឲ្យតែឃេមខ្មោរៀងត្រជាក់ចេះហ៊ូល ។

ប៊ុនថនៈ ចុកអីពូ?

ជិនៈ បាទ!ហ៊ូលជើងព្រឹកមិញហ្នឹងរៀបដឹកកណ្ដាប់អីំនេះហើយបរទេះទៅដឹកកណ្ដាប់អីំតិតត់ៗ ។

ប៊ុនថនៈ ចឹងខ្ញុំអស់អីសួរពូហើយអរគុណច្រើន ។

ជិនៈ បាទ ។

«ចប់»